# ក្រុមការងារជនពិការក្រសួង សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ចុះធ្វើទស្សនកិច្ចស្វែងយល់អំពីស្ថានភាពបងប្អូនកម្មករ កម្មការិនីដែលជាជនពិការ



កាលពីរសៀល ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រុមការងារសកម្មភាពជនពិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដឹកនាំដោយ**ឯកឧត្តម អ៊ុំ សុថា** អនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមការងារ សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ នាយកដ្ឋានសុខុមាលភាពជនពិការ និងរដ្ឋបាលសិទ្ធិជនពិការ បានធ្វើទស្សនកិច្ចស្វែងយល់អំពីស្ថានភាពនៃការបំពេញការងាររបស់បងប្អូនកម្មករ កម្មការិនីដែលជាជនពិការ នៅរោងចក្រស្បែកជើង ស៊ីម៉ាណូ ស្ថិតនៅទីប្រជុំជនព្រៃផ្តៅ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ តាមរយៈការចុះពិនិត្យដោយផ្ទាល់បានបង្ហាញឱ្យឃើញថារោងចក្រមួយនេះ បានយកចិត្តទុកដាក់ជាខ្លាំងក្នុងការផ្តល់ឱកាស និងលទ្ធភាពដល់ជនពិការ អាចចូលបម្រើការងារបាន

និងទទួលបានអត្ថប្រយោជន៍សមស្រប ដូចអ្នកដទៃទៀតដែរ។ មិនតែប៉ុណ្ណោះ ទទួលបានការផ្តល់អាទិភាពក្នុងការស្នាក់នៅក្នុងរោងចក្រ, មានលទ្ធភាពចេញមុនម៉ោងកំណត់ ៧ ឬ ១០នាទី, មានទីកន្លែងធ្វើការ បន្ទប់ទឹក បង្គន់អនាម័យ, កន្លែងទទួលទានអាហារ, ផ្លូវដើរសម្រាប់ជនពិការ ដែលសម្រួលដល់ការប្រើប្រាស់របស់ជនពិការបានជាធម្មតា។




រោងចក្រនេះ មានអត្រាជនពិការបម្រើការងារប្រមាណ១៧% នៃចំនួនកម្មករសរុប ប្រមាណជា ៨៥០នាក់ ពោលគឺអនុវត្តបានលើសពីអត្រាកំណត់របស់រាជរដ្ឋាភិបាល ដែលបានកំណត់យ៉ាងតិចបំផុត ត្រូវមានជនពិការបម្រើការងារក្នុងរោងចក្រ សហគ្រាសឯកជនចំនួន ១%។

មានមតិក្នុងឱកាសនោះ **ឯកឧត្តម អ៊ុំ សុថា** បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងការកោតសរសើរដ៏ស្មោះ ចំពោះបងប្អូនជនពិការ ដែលបានអត់ធ្មត់ តស៊ូ ជម្នះរាល់ការលំបាកនានា ខិតខំបំពេញការងារជូនរោងចក្របានល្អ បង្កើតស្នាដៃធំធេង ក្នុងការផលិតចេញជាផលិតផលរបស់ខ្មែរ នាំចេញទៅលក់នៅទីផ្សារបរទេស។ ក្រសួងសង្ឃឹមដែរថា ដោយមាន

ការចូលរួមចំណែកពីស្នាដៃរបស់ជនពិការកម្ពុជា អ្នកបញ្ជាទិញនៅក្រៅប្រទេសនឹងជួយគាំទ្រ និងលើកទឹកចិត្តក្នុងការជ្រើសរើសរោងចក្រនេះ ធ្វើជាដៃគូផ្គត់ផ្គង់ផលិតផលដល់ទីផ្សាររបស់ពួកគេ ហើយប្រការនេះ ក៏នឹងក្លាយជាគំរូល្អ សម្រាប់រោងចក្រដទៃទៀត ក្នុងការចូលរួមទាំងអស់គ្នា លើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងច្បាប់ ស្ដីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

ក្នុងនាមក្រុមប្រឹក្សាសកម្មភាពជនពិការ **លោកជំទាវ ប្រាក់ ធារ៉ៈភារី** អគ្គលេខាធិការរងក្រុមប្រឹក្សាសកម្មភាពជនពិការ បានវាយតម្លៃខ្ពស់ចំពោះគំរូដ៏ល្អរបស់រោងចក្រ និងចាត់ទុកថានេះជាការចូលរួមអនុវត្ត ប្រកបដោយលទ្ធផលល្អជាវិជ្ជមាន ចំពោះការអនុវត្តអត្រាកំណត់ក្នុងការជ្រើសរើសជនពិការចូលបម្រើការងារក្នុងផ្នែកឯកជន ដែលយើងសូមលើកទឹកចិត្តដល់រោងចក្រដទៃទៀត ឱ្យខិតខំអនុវត្តតាមរបៀបនេះ។ ទន្ទឹមនឹងនេះ ត្រូវបន្តជួយសម្រួលដល់ជនពិការ ក្នុងការទទួលបានឱកាសការងារ និងបង្ករលក្ខណៈដល់ជនពិការ មានលទ្ធភាពប្រើប្រាស់ទីកន្លែងធ្វើការ ទីកន្លែងសម្រាក ឬពិនិត្យព្យាបាលជំងឺ, ធ្វើដំណើរទៅមក បានងាយស្រួល។

